ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

ចូល
លេខ: ...
មកដល់ថ្ងៃ ... ខែ ... ឆ្នាំ ...
ម៉ោង ...

សាលាខេត្តបាត់ដំបង

លេខ: ០០៣/១៦ សក.បក

# ដីកា

## ស្តីពីការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅថ្នាក់រដ្ឋបាលខេត្តបាត់ដំបង ដើម្បីជម្រុញការអនុវត្ត ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្ត កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៥-២០១៨

## អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១១៤/០៧៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៤ ត្រាស់បង្គាប់តែងតាំងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង

-បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីតួនាទីភារកិច្ច និង ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និង ក្រុមប្រឹក្សា គណៈអភិបាលស្រុក

-យោងលិខិតលេខ ១៥២០ សជណ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃស្តីពីការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត ដើម្បីជម្រុញការអនុវត្ត ការតាមដានត្រួតពិនិត្យ និង ការវាយតម្លៃ ការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ២០១៥-២០១៨

-យោងតាមការចាំបាច់របស់រដ្ឋបាលខេត្ត

## សម្រេច

**ប្រការ១.-**

បង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅថ្នាក់រដ្ឋបាលខេត្តបាត់ដំបង ដើម្បីជម្រុញការអនុវត្ត ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ ២០១៥-២០១៨ ។/.

**ប្រការ២.-**

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅថ្នាក់រដ្ឋបាលខេត្តបាត់ដំបង មានសមាសភាព ដូចខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | **ហឿន សុគន្ធ** | អភិបាលរង នៃគណៈអភិបាលខេត្ត | ជាប្រធាន |
| ២- | លោក | **សឿម ម៉ុនរិទ្ធិ** | នាយករដ្ឋបាលសាលាខេត្ត | ជាអនុប្រធាន |
| ៣- | លោក | **ស៊ូ គឹមព្រិទ្ធី** | ប្រធានមន្ទីរមុខងារសាធារណៈខេត្ត | ជាអនុប្រធានអចិន្ត្រៃយ៍ |
| ៤- | លោក | **ប៉ោទ្រី ឡឿន** | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | ជាសមាជិក |
| ៥- | លោក | **ស៊ីវ៉ុន ខេមរុន** | ប្រធានរតនាគារខេត្ត | ជាសមាជិក |
| ៦- | លោក | **នុត ប៊ុណ្ណា** | ប្រធានអង្គភាពលទ្ធកម្មសាលាខេត្ត | ជាសមាជិក |
| ៧- | លោក | **មូល ធន** | នាយកទីចាត់ការផែនការ និងវិនិយោគសាលាខេត្ត | ជាសមាជិក |
| ៨- | លោក | **នាង ច័ន្ទថារ៉ា** | នាយកទីចាត់ការអន្តរវិស័យសាលាខេត្ត | ជាសមាជិក |
| ៩- | លោក | **អ៊ុកវង្ស ឡុងវី** | នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្សសាលាខេត្ត | ជាសមាជិក |
| ១០- | លោកស្រី | **កែវ ដាណា** | នាយកទីចាត់ការរដ្ឋបាលសាលាខេត្ត | ជាសមាជិកា |
| ១១- | លោក | **ខន ធិរៈ** | នាយកស្តីទីទីចាត់ការហិរញ្ញវត្ថុសាលាខេត្ត | ជាសមាជិក |
| ១២- | លោក | **សៀងឯម ខុនស្ពី** | អភិបាលនៃគណៈអភិបាលក្រុងបាត់ដំបង | ជាសមាជិក |
| ១៣- | លោក | **ជុំ ញ៉ូ** | អភិបាលនៃគណៈអភិបាលស្រុកបាណន់ | ជាសមាជិក |
| ១៤- | លោក | **គង់ លី** | អភិបាលនៃគណៈអភិបាលស្រុកថ្មគោល | ជាសមាជិក |
| ១៥- | លោក | **ឡុង សុភីន** | អភិបាលនៃគណៈអភិបាលស្រុកឯកភ្នំ | ជាសមាជិក |
| ១៦- | លោក | **គឹម វណ្ណៈ** | អភិបាលនៃគណៈអភិបាលស្រុកសង្កែ | ជាសមាជិក |
| ១៧- | លោក | **ឡាំ សោម** | អភិបាលនៃគណៈអភិបាលស្រុកមោងឫស្សី | ជាសមាជិក |
| ១៨- | លោក | **ផន្ទ សៅឫទ្ធិ** | អភិបាលនៃគណៈអភិបាលស្រុកសំឡូត | ជាសមាជិក |
| ១៩- | លោក | **ជា សុផាត** | អភិបាលនៃគណៈអភិបាលស្រុកកំរៀង | ជាសមាជិក |
| ២០- | លោក | **សួន គឿន** | អភិបាលនៃគណៈអភិបាលស្រុកភ្នំព្រឹក | ជាសមាជិក |
| ២១- | លោក | **ជា សម្បត្តិ** | អភិបាលនៃគណៈអភិបាលស្រុកសំពៅលូន | ជាសមាជិក |
| ២២- | លោក | **ទឹម ដារ៉ែត** | អភិបាលនៃគណៈអភិបាលស្រុកបវេល | ជាសមាជិក |
| ២៣- | លោក | **សើ សាម៉េត** | អភិបាលនៃគណៈអភិបាលស្រុករតនមណ្ឌល | ជាសមាជិក |
| ២៤- | លោក | **ផេង សិទ្ធី** | អភិបាលនៃគណៈអភិបាលស្រុកគាស់ក្រឡ | ជាសមាជិក |
| ២៥- | លោក | **ពេជ ម៉ាឡៃ** | អភិបាលនៃគណៈអភិបាលស្រុករុក្ខគិរី | ជាសមាជិក |
| ២៦- | លោក | **ជា ហាប់** | អនុប្រធានមន្ទីរមុខងារសាធារណៈខេត្ត | ជាសមាជិក |
| ២៧- | លោក | **កែវ មូរ៉ា** | អនុប្រធានការិយាល័យ នៃមន្ទីរមុខងារសាធារណៈខេត្ត | ជាសមាជិក |

**ប្រការ៣.-**

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅថ្នាក់រដ្ឋបាលខេត្តបាត់ដំបង ដើម្បីជម្រុញការអនុវត្ត ការតាមដានត្រួតពិនិត្យ និង ការវាយតម្លៃការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៥-២០១៨ មានតួនាទី ភារកិច្ច ដូចខាងក្រោម ៖

-ទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សា និងគណៈអភិបាលខេត្ត ក្នុងការគ្រប់គ្រង និងដឹកនាំគ្រប់ការងារពាក់ព័ន្ធនឹងកម្មវិធីយុទ្ធសាស្ត្រ និងសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈរបស់ថ្នាក់ក្រោមជាតិ ។

-សម្របសម្រួលការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ថ្នាក់ក្រោមជាតិ ជាមួយក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ។

-សម្របសម្រួលនិងជម្រុញការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពការងារ កែទម្រង់រដ្ឋបាលសាធារណៈ ។

-រៀបចំផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខេត្ត ។

-រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពឲ្យបានទៀតទាត់រៀងរាល់ត្រីមាសមកលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ។

-រៀបចំរបាយការណ៍ ស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈជូនក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈក្រសួងមហាផ្ទៃ ដើម្បីធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជ្រាប និង ផ្តល់គោលការណ៍ណែនាំអនុវត្ត ។

-ផ្តល់កិច្ចសហការ និង សម្របសម្រួលជាមួយលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈតាមរយៈមន្ត្រីបង្គោលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។

-តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**ប្រការ៤.-**

នាយករដ្ឋបាលសាលាខេត្ត ប្រធានមន្ទីរមុខងារសាធារណៈខេត្ត ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ប្រធានរតនាគារខេត្ត ប្រធានអង្គភាពលទ្ធកម្ម នាយកទីចាត់ការផែនការ និងវិនិយោគ នាយកទីចាត់ការអន្តរវិស័យ នាយកទីចាត់គ្រប់គ្រងធនធានមនុស្ស នាយកទីចាត់ការរដ្ឋបាល នាយកទីចាត់ការហិរញ្ញវត្ថុនៃសាលាខេត្ត អភិបាលនៃគណៈអភិបាលក្រុង-ស្រុកក្នុងខេត្ត ប្រធានមន្ទីរ អង្គភាពដែលមានការពាក់ព័ន្ធ ព្រមទាំងឯកឧត្តម លោក លោកស្រី ដូចមានឈ្មោះក្នុងប្រការ២ត្រូវអនុវត្តដីកានេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

បាត់ដំបង,ថ្ងៃទី ១២ ខែសីហា ឆ្នាំ២០១៦

**អភិបាលខេត្ត**

ច័ន្ទ សុផល

**ចម្លងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងមុខងារសាធារណៈ
-ក្រសួងស្ថាប័នពាក់ព័ន្ធ
-លេខាធិការដ្ឋាន គ.ជ.អ.ប
-លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
-ក្រុមប្រឹក្សាខេត្តបាត់ដំបង

"**ដើម្បីគោរពជូនជ្រាប**"

-ដូចប្រការ៤

"**ដើម្បីអនុវត្ត**"

-ឯកសារ-កាលប្បវត្តិ